នស/រកត/០២០៥/០៩៧

# ព្រះរាជក្រឹត្យ

## ស្តីពី

## ការកែសម្រួល មាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និង មាត្រា១៦ នៃព្រះរាជក្រឹត្យ ស្តីពី ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែល ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

# ត្រាស់បង្គាប់

**មាត្រាមួយ .-**

មាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និង មាត្រា១៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា ត្រូវបានកែសម្រួល ដូចខាងក្រោម :

**មាត្រា១០ ថ្មី.-**

**គ.ឧ.ក** មានសមាជិកអចិន្ត្រៃយ៍ និង សមាជិកជ្រើសតាំង ។

ក. សមាជិកអចិន្ត្រៃយ៍

សមាជិកអចិន្ត្រៃយ៍រួមមាន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា។ ឥស្សរជនទាំងពីររូបត្រូវធ្វើជា ប្រធាន ឬ អនុប្រធាន **គ.ឧ.ក**។ ឥស្សរជនដែលមានតំណែងខ្ពស់ជាងក្នុងរាជរដ្ឋាភិបាល ត្រូវធ្វើជាប្រធាន **គ.ឧ.ក** ហើយឥស្សរជន ដែលមានតំណែងទាបជាងត្រូវធ្វើជាអនុប្រធាន **គ.ឧ.ក**។ ក្នុងករណីដែលឥស្សរជនទាំងពីររូប មានតំណែងស្មើគ្នាក្នុងរាជរដ្ឋាភិបាល ប្រធាន **គ.ឧ.ក** ត្រូវជ្រើសរើសតាមរយៈការបោះឆ្នោត របស់សមាជិកជ្រើសតាំងទាំងប្រាំរូប ដោយសម្លេងភាគច្រើនដាច់ខាត ហាសិប បូក មួយ ។

ខ.សមាជិកជ្រើសតាំង

សមាជិកជ្រើសតាំងមានប្រាំរូប ដែលត្រូវជ្រើសរើសចេញពីឥស្សរជនកម្ពុជាដែលមានសញ្ញាប័ត្រឧត្តមសិក្សា និងមានជំនាញផ្នែកគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា ឬមានជំនាញក្នុងការកសាងគោលនយោបាយ ផ្នែកឧត្តមសិក្សា តាមរយៈនីតិវិធីដូចបានកំណត់ក្នុងមាត្រា ១៤ថ្មី ១៥ថ្មី និង ១៦ថ្មី នៃព្រះរាជក្រឹត្យនេះ ឬមាត្រា ៦២ នៃព្រះរាជក្រឹត្យលេខនស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ខែ មីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា។

**គ.ឧ.ក** មានអ្នកជំនាញពីររូប ដែលមានបទពិសោធន៍នៅក្នុងស្ថាប័នទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា នៃប្រទេសនានាជាទីប្រឹក្សា ។

**មាត្រា១១ ថ្មី.-**

សមាជិក **គ.ឧ.ក** ទាំងអស់ត្រូវជ្រើសតាំងឱ្យបំរើការងារមិនពេញម៉ោង និង ទទួលប្រាក់ឧបត្ថម្ភ តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ។ ប្រាក់ឧបត្ថម្ភ របស់សមាជិក **គ.ឧ.ក** ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ប្រធាន **គ.ឧ.ក** ។

**គ.ឧ.ក**មានអគ្គលេខាធិការដ្ឋានមួយចំណុះផ្ទាល់ទីស្តីការគណៈរដ្ឋមន្ត្រី។ អគ្គលេខាធិការដ្ឋាន **គ.ឧ.ក** ដឹកនាំដោយអគ្គលេខាធិការ១រូបមានឋានៈស្មើអនុរដ្ឋលេខាធិការនិងអមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ តាមការចាំបាច់ ។ សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាន នៃ **គ.ឧ.ក** នឹងកំណត់ដោយអនុក្រឹត្យ ។

**គ.ឧ.ក** មានបទបញ្ជាផ្ទៃក្នុង ឡូហ្គោ និង ត្រាមួយដោយឡែករបស់ខ្លួន ។

**មាត្រា១៤ ថ្មី.-**

ដើម្បីជ្រើសតាំងសមាជិក **គ.ឧ.ក** ប្រធាន **គ.ឧ.ក** ត្រូវបង្កើតគណៈកម្មការស្នើតាំងមួយសម្រាប់ជ្រើសតាំងបេក្ខភាពតំណាងសមាជិក **គ.ឧ.ក**។ ដើម្បីឱ្យដំណើរការជ្រើសតាំងនេះ ប្រព្រឹត្តទៅបានប្រសិទ្ធភាពខ្ពស់ ប្រធាន **គ.ឧ.ក** ត្រូវជូនដំណឹងទៅគណៈកម្មការស្នើតាំងឱ្យធ្វើការស្នើតាំងបេក្ខជន សម្រាប់តំណែងសមាជិក **គ.ឧ.ក** ។

**មាត្រា១៥ ថ្មី.-**

ក្នុងការជ្រើសតាំង បេក្ខភាពតំណែងសមាជិក **គ.ឧ.ក** គណៈកម្មការស្នើតាំង ត្រូវធ្វើការជ្រើសតាំងតាមរយៈការបោះឆ្នោត ដោយយកសំឡេងភាគច្រើនដាច់ខាត ហាសិប បូក មួយ ។ បន្ទាប់មក គណៈកម្មការនេះ ត្រូវបញ្ជូនបញ្ជីឈ្មោះបេក្ខជនជាប់ឆ្នោតប្រាំរូបទៅ ប្រធាន **គ.ឧ.ក** ។ ផ្អែកលើបញ្ជីឈ្មោះបេក្ខជនជាប់ឆ្នោតនោះ ប្រធាន **គ.ឧ.ក** ត្រូវរៀបចំស្នើសុំតែងតាំង សមាជិក **គ.ឧ.ក** ដោយព្រះរាជក្រឹត្យ។ គណៈកម្មការស្នើតាំង ក៏មានភារកិច្ចធ្វើការស្នើតាំងសមាសភាពថ្មីផងដែរ ពេលណាមានតំណែងនៃសមាជិក **គ.ឧ.ក** ណាមួយដែលទំនេរ ។

**មាត្រា១៦ ថ្មី.-**

សមាសភាពនៃគណៈកម្មការស្នើតាំងមានដូចតទៅ :

- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី មួយរូប ប្រធាន
- តំណាងក្រសួងអប់រំ យុវជន និងកីឡា មួយរូប អនុប្រធាន

- សាកលវិទ្យាធិការ ឬ ព្រឹទ្ធបុរស ឬ នាយក នៃគ្រឹះស្ថានឧត្តមសិក្សាដែលទទួលការ អនុញ្ញាតជាផ្លូវការពីរាជរដ្ឋាភិបាល មួយរូប សមាជិក
- តំណាងក្រសួងអាណាព្យាបាលនៃគ្រឹះស្ថានឧត្តមសិក្សានីមួយៗ សមាជិក

គណៈកម្មការស្នើតាំងមានសិទ្ធិអញ្ជើញឱ្យចូលរួមជាអ្នកសង្កេតការណ៍ :

- តំណាងម្ចាស់ជំនួយបរទេស ដែលនាំមុខគេផ្នែកឧត្តមសិក្សា បីរូប
- តំណាងមកពីភ្នាក់ងារសាកលវិទ្យាល័យប្រើភាសាបារាំង AUF មួយរូប
- តំណាងមកពីបណ្តាញសមាគមសាកលវិទ្យាល័យអាស៊ាន ASEAN University Network មួយរូប
- តំណាងមកពីអង្គការស៊ីម៉េអូរ៉ាយហេត SEAMEO RIHED មួយរូប ។

**មាត្រាពីរ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រាបី .-**

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រាបួន .-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត.០២០៥.១០០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ២០០៥

លេខ ៧៧៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ាន់ តាន់